# ក

## មាតិកា

## I~ ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៧-៧-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៧០៣/២៣៦ ស្តីពីការប្រោសព្រះរាជទាន ចំពោះ ឧកញ៉ា **កែវ ឡា** នូវគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** ២៧៨៤

២៤-៧-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៧០៣/២៤៣ ស្តីពីការប្រោសព្រះរាជទានៈ
ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ចំពោះ ឯកឧត្តម ០៦ រូប
ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ចំពោះ ឯកឧត្តម ០៣ រូប ២៧៨៥

២៤-៧-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៧០៣/២៤៤ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **វ៉ាង ស៊ូចេង** ( WANG SHOU-CHENG ) សញ្ជាតិចិន កើតនៅកោះតៃវ៉ាន់ ប្រទេសចិន ២៧៨៦

២៤-៧-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៧០៣/២៤៥ ស្តីពីការតម្លើងឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ចំពោះឧត្តមសេនីយ៍ទោ **ជាំ ឫទ្ធី** នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ២៧៨៧


## II- រាជរដ្ឋាភិបាល

### ១~ អនុក្រឹត្យ


២៥-៧-២០០៣ - អនុក្រឹត្យលេខ ៥៨ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ២៧៨៨

២៥-៧-២០០៣ - អនុក្រឹត្យលេខ ៧២៤ អនក្រ.តត ស្តីពីការ បំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូន ឯកឧត្តម **អ៊ីស្សេ អ៊ីណូអេ** ( Issei Inoue) អតីតរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជប៉ុន ២៧៩០

២៥-៧-២០០៣ - អនុក្រឹត្យលេខ ៧២៥ អនក្រ.តត ស្តីពីការ បំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូន ឯកឧត្តម **អូសាមុ យ៉ាម៉ាម៉ូតូ** ( Osamu Yamamoto) ប្រធានក្រុមអនាម័យអូសាកា និងទូរគមនា គមន៍ ជប៉ុន ២៧៩១


## III- ការងារបណ្តាក្រសួង

### ១~ ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


២៣-៧-២០០៣ - ប្រកាសណែនាំលេខ ៤៨២ សហវ-ប្រក ស្តីពីនីតិវិធីបច្ចេកទេស នៃការរៀបចំគំរោងថវិកា ខេត្ត ក្រុង ឆ្នាំ ២០០៤ ២៧៩២

# ខ


២៨-៧-២០០៣ - ប្រកាសលេខ ៥០៧ សហវ.ឧហ ស្តីពី ការដកហូតអាជ្ញាប័ណ្ណជាបណ្តោះអាសន្ន របស់ក្រុមហ៊ុនឆ្នោត **ហ្វាំឈូន ឡូធើរី** ២៧៩៨

២៨-៧-២០០៣ - ប្រកាសលេខ ៥០៨ សហវ.ឧហ ស្តីពី ការដកហូតអាជ្ញាប័ណ្ណជាបណ្តោះអាសន្ន របស់ក្រុមហ៊ុនឆ្នោត **ជា អ៊ីន អន្តរជាតិ** ២៨០០

២៩-៧-២០០៣ - ប្រកាសអន្តរក្រសួងលេខ ៥០៩ សហវ ស្តីពី ការបង្កើតរដ្ឋទេយ្យបុរេប្រទាននៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ២៨០២


## ២_អាជ្ញាធរសវនកម្មជាតិ


២៥-៧-២០០៣ -សេចក្តីសំរេចលេខ ០៥៧/០៣ អសជ/សសរ ស្តីពី សវនកម្មគណនី និងសវនកម្មប្រតិបត្តិការរបស់ឃុំ-សង្កាត់ ២៨០៤


## ៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងយុវជន និង កីឡា


២៥-៧-២០០៣ -ប្រកាសលេខ ៧៥៧ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ មិត្តភាពខ្មែរន័រវែហ្វ ចំប៉ាស្ថិតនៅក្នុងឃុំចំប៉ា ស្រុកព្រៃកប្បាស ខេត្តតាកែវ ២៨០៨

២៥-៧-២០០៣ -ប្រកាសលេខ ៧៥៨ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ហ៊ុន សែន សិរីវង្ស ស្ថិតនៅក្នុងឃុំសោម ស្រុកគីរីវង្ស ខេត្តតាកែវ ២៨០៩

២៥-៧-២០០៣ -ប្រកាសលេខ ៧៥៩ អយក.ប្រក ស្តីពីការប្តូរឈ្មោះវិទ្យាល័យ " អង្គប្រីយ៍ " ទៅជាវិទ្យាល័យ " ហ៊ុន សែន អង្គប្រីយ៍ " ស្ថិតនៅក្នុងឃុំ បាលំចង់ ស្រុកសំរោង ខេត្តតាកែវ ២៨១០

២៥-៧-២០០៣ -ប្រកាសលេខ ៧៦០ អយក.ប្រក ស្តីពីការពង្រីកអនុវិទ្យាល័យ " ហ៊ុន សែន ១ មិថុនា " ទៅជាវិទ្យាល័យ " ហ៊ុន សែន ១ មិថុនា " ស្ថិតនៅក្នុងឃុំពារាម ស្រុកបាទី ខេត្តតាកែវ ២៨១១

២៥-៧-២០០៣ -ប្រកាសលេខ ៧៦១ អយក.ប្រក ស្តីពីការពង្រីកអនុវិទ្យាល័យ " ហ៊ុន សែន ឈើទាល " ទៅជាវិទ្យាល័យ " ហ៊ុន សែន ឈើទាល " ស្ថិតនៅក្នុងឃុំរកាក្រៅ ស្រុកដូនកែវ ខេត្តតាកែវ ២៨១២

# ព្រះរាជក្រឹត្យ

នស/រកត/០៧០៣/២៣៦

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា )

**ប្រោសព្រះរាជទាន**

**ចំពោះ**

ឧកញ៉ា **កែវ ឡា**

នូវ

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខ : ២០២ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០០៣

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

ប្រាក់ សុខុន

ពរស.០៣.០៧.២៤៧

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៣*

# ព្រះរាជក្រឹត្យ

នស/រកត/០៧០៣/២៤៣

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា )

**ប្រោសព្រះរាជទាន**

ក - គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ចំពោះ :

១- ឯកឧត្តម **មល់ រឿប**

២- ឯកឧត្តម **ហ៊ុយ ពិសិដ្ឋ**

៣- ឯកឧត្តម **ហ៊ីង ប៊ុនហៀង**

៤- ឯកឧត្តម **ហ៊ុន ស៊ីថា**

៥- ឯកឧត្តម **យូ ស៊ុនឡុង**

៦- ឯកឧត្តម **លីម លាងសែ**

ខ - គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ចំពោះ :

១- ឧត្តមសេនីយ៍ឯក **ខ្វាន់ ស៊ាម**

២- ឧត្តមសេនីយ៍ត្រី **គង់ អៀង**

៣- ឧត្តមសេនីយ៍ត្រី **អ៊ុច វណ្ណថា**

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ** លេខ : ២០៧ ច.ល

**នរោត្តម សីហនុ**

ដើម្បីចម្លងចែក

តរស.០៣.០៧.២៥៤

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៣*

**ប្រាក់ សុខុន**

# ព្រះរាជក្រឹត្យ

នស/រកត/០៧០៣/២៤៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **វ៉ាង ស៊ូចេង** ( WANG SHOU-CHENG ) សញ្ជាតិចិន កើតថ្ងៃទី ១២ ខែ មីនា ឆ្នាំ ១៩៥៨ នៅកោះតៃវ៉ាន់ ប្រទេសចិន ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

៣រល.០៣.០៧.៤៥៥

លេខ : ២០១ ច.ល

ដើម្បីចម្លងចែក

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៣*

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០០៣

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សុខ អាន

# ព្រះរាជក្រឹត្យ

នស/រកត/០៧០៣/២៤៥

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** តម្លើងឋានន្តរសក្តិ ថ្នាក់ ឧត្តមសេនីយ៍ឯក ចំពោះឧត្តមសេនីយ៍ទោ ជាំ ឌុទ្ធី អត្តលេខ ០០០០៤៨ នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា និង ព្រះរាជលញ្ចករ**

**នរោត្តម សីហនុ**

៣៣៧.០៣.០៧.២៤៦

លេខ : ២០០ ច.ល

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៣*

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០០៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស្វាយ សុខុន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ , ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១០/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០២/០២១ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៣
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក , ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០២ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ២.៩០០ លានរៀល ( ពីរពាន់ប្រាំបួនរយលានរៀលគត់ ) ពីជំពូក ៤០ ( ចំណាយផ្សេងៗ ) សង VAT មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច ) របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយដំណើរការរដ្ឋបាល ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីគោរពជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧២៤ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## ស ំ រ េ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនឯកឧត្តម **អ៊ីសេ្ស អ៊ីណូអេ** (Issei Inoue) អតីតរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ជប៉ុន ដែលបានស្វែងរក និងផ្តល់ជំនួយដ៏ច្រើនសំរាប់ជួយកសាង និងអភិវឌ្ឍវិស័យអប់រំ នៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៣*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*
- *រាជកិច្ច* ✓
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៧២៥ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនលោក **អូសាមុ យ៉ាម៉ាមូតូ** **(Osamu Yamamoto)** ប្រធានក្រុមហ៊ុនអនាម័យអូសាកា ដែលបានស្វែងរក និងផ្តល់ជំនួយដ៏ច្រើនសំរាប់ជួយកសាង និងអភិវឌ្ឍវិស័យអប់រំ នៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៣*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*
- *រាជកិច្ច* ✔
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ: ៤៨២ សហវ.ណភក

# ប្រកាសណែនាំ
## ស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគំរោងថវិកា
## ខេត្ត ក្រុងឆ្នាំ ២០០៤

យោងប្រកាសលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីបទបញ្ញាថវិការបស់ខេត្ត ក្រុង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគំរោងថវិកាខេត្ត ក្រុង ឆ្នាំ ២០០៤ ដូចតទៅ ÷

### I. ការរៀបចំចំណូលថវិកា :

1. ការគិតគូរចំណូលចរន្តរបស់ថវិកាខេត្ត ក្រុង អាស្រ័យទៅលើប្រភពនៃផលិតផល ឬ ផលទុន ដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ។

ផ្អែកតាមប្រភពធនធានខាងលើនេះ អភិបាលខេត្ត ក្រុងត្រូវរៀបចំនូវគំរោងចំណូលថវិការបស់ខេត្ត ក្រុងសាមីដូចតទៅ ÷

- ចំណូលសារពើពន្ធ ត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម ÷
  + លទ្ធផលដែលទទួលបាននៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ
  + ផលប៉ះពាល់នៃអតិផរណាមកលើមូលដ្ឋានពន្ធ
  + ប៉ាន់ស្មានលើការវិវឌ្ឍន៍សេដ្ឋកិច្ចនៅពេលខាងមុខ
  + ការប្រែប្រួលដែលអាចកើតមានឡើង ឬត្រូវពិនិត្យពិចារណាលើអត្រា និង មូលដ្ឋានប្រមូលពន្ធ
  + ចំណូលដែលសង្ឃឹមថាបានមកពីការបង្កើតពន្ធថ្មី (ករណីមានគោលនយោបាយថ្មី) ។
- ទន្ទឹមនឹងនេះ ចំណូលពុំមែនសារពើពន្ធ ត្រូវបានគិតគូរទៅតាមកិច្ចការដែលនាំអោយមានផលទុន ដូចជាកិច្ចសន្យាជួល សេវាកម្ម។ល។ ចំណូលទាំងអស់នេះ ត្រូវផ្អែកលើមូលដ្ឋានតួលេខស្ថិតិសំរេចបាននៃឆ្នាំកន្លងមក និងការវិវឌ្ឍន៍នៃសេដ្ឋកិច្ច ។

ចំពោះនីតិវិធី គឺអភិបាលខេត្ត ក្រុង ត្រូវអញ្ជើញមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សាខាពន្ធដារ និងមន្ទីរជំនាញដែលពាក់ព័ន្ធ ក្នុងការប្រមូលចំណូលសារពើពន្ធនិងពុំមែនសារពើពន្ធ សំរាប់ថវិកាខេត្ត ក្រុង ដើម្បីមកចូលរួមពិភាក្សាគិតគូររៀបចំជាគំរោងចំណូលសរុប ទៅតាមតារាងឧបសម្ព័ន្ធទី១ ដែលជូនភ្ជាប់មកជាមួយនេះ ។

2. ចំណូលផ្ទេរក្នុងជាមូលធនរបស់ថវិកាខេត្ត ក្រុង ក្នុងករណីដែលមាន គឺត្រូវយកចិត្តទុកដាក់បញ្ចូលទៅក្នុងគំរោងចំណូល ។ ទន្ទឹមនឹងនេះ ក៏ត្រូវយកចិត្តទុកដាក់កត់ត្រាបញ្ចូលនូវចំណូលពីជំនួយមនុស្សធម៌ និងជំនួយពីបរទេស

ដែលសប្បុរសជន អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានា បានទៅទំនាក់ទំនងផ្ទាល់ជាមួយខេត្ត ក្រុង រួចហើយនោះ ។

## II. ការរៀបចំចំណាយថវិកា

3. ខេត្ត ក្រុងត្រូវរៀបចំនូវគំរោងចំណាយសំរាប់រាល់សកម្មភាពសេវាទាំងអស់ដោយកាត់បន្ថយមុខចំណាយណាដែលពុំចាំបាច់ ដែលស្ថិតនៅក្រោមនិវាទរបស់ខ្លួន ។ របៀបគិតគូរនូវតំរូវការនានា គឺជាការកំណត់នូវមុខចំណាយនីមួយៗដោយច្បាស់លាស់ និងដោយផ្អែកទៅ លើកត្តានានា ដែលទាក់ទងផ្ទាល់ទៅនឹងមុខចំណាយនោះ ដូចជា តារាងបុគ្គលិក បញ្ជីចាត់ស្មាទបរិមាណ តំលៃ សម្ភារៈ ឬសេវា... ។ ចំពោះសកម្មភាពមួយចំនួនទាមទារអោយមានបង្កើតធម្មនិយាមសមស្រប ដូចជា ចំណាយជួសជុលក្នុងមួយម៉ែត្រការ៉េ ចំនួនទឹកប្រាក់ចាំបាច់ សំរាប់ថ្ងៃក្រឡាណាមួយ ការប្រើប្រាស់គ្រឿងចក្រគិតជា ប្រេងឥន្ធនៈ ការសឹករិចរឹលនៃសំបកកង់រថយន្តគិតជាគីឡូម៉ែត្រជាដើម។ ចំពោះសម្ភារៈបរិក្ខារដែលប្រើប្រាស់ជាប្រចាំ ត្រូវគិតគូរដោយផ្អែកតាមតួលេខស្ថិតិគណនេយ្យថវិកាជាមធ្យមភាគនៃបណ្តាឆ្នាំកន្លងមក ។ ចំណែកឯ សោហ៊ុយធ្វើដំណើរ ស្នាក់នៅ បេសកកម្ម ត្រូវផ្អែកលើរបបកំណត់ជាធរមាន (អនុក្រឹត្យលេខ ០៧ អនក្រ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីការកំណត់ប្រាក់របបបេសកកម្មក្នុងប្រទេស) ។

គំរោងចំណាយទាំងអស់របស់ថវិកាខេត្ត ក្រុង ត្រូវបានសរុបនៅក្នុងតារាងឧបសម្ព័ន្ធទី២ ដែលជូនភ្ជាប់មកជាមួយនេះ ។

4. ជាទូទៅ សំណើចំណាយទាំងអស់ត្រូវតែមានការវិភាគ និងមានលិខិតយុត្តិការភ្ជាប់មកជាមួយ តាមជំពូក ប្រការ កថាខ័ណ្ឌ និងវាក្យខ័ណ្ឌ ដើម្បីបង្ហាញអោយឃើញថា ការគិតគូរចំណាយរបស់ខ្លួនមានភាពត្រឹមត្រូវ ហ្មត់ចត់និងសមហេតុផល ។ លិខិតយុត្តិការទាំងអស់នេះ នឹងធ្វើជាមូលដ្ឋាននៃការពិនិត្យពិភាក្សាថវិកា ។

5. ប្រកាសណែនាំនេះ ក៏មានភ្ជាប់ជាមួយនូវសលាកប័ត្រគំរូមួយចំនួនសំរាប់បំពេញនូវឥណទាន ដែលត្រូវស្នើសុំទៅតាមមុខចំណាយនីមួយៗ ។ សលាកប័ត្រទាំងអស់នេះ ត្រូវបានអង្គភាពទាទាររបស់ខេត្ត ក្រុង ប្រើប្រាស់សំរាប់ផ្តល់នូវព័ត៌មានបន្ថែម ទៅលើការស្នើសុំឥណទានរបស់ខ្លួន ។

### II.1 ការរៀបចំគំរោងចំណាយចរន្ត

6. លិខិតយុត្តិការនៃចំណាយចរន្តមានគោលដៅសំខាន់ៗដូចតទៅ ÷

## ប្រភេទ ១ : មធ្យោបាយសេវា

### ជំពូក១០ : ប្រាក់បៀវត្ស និង ប្រាក់បំណាច់

7. ចំណាយសំរាប់បុគ្គលិកត្រូវតែគិតគូរអោយបានច្បាស់លាស់ ។ ចំណាយលើជំពូកនេះ ត្រូវបានចាត់ទុកជាចំណាយដែលមានអាទិភាពបំផុតក្នុងការរៀបចំគំរោងថវិកា ។ ចំណាយនេះត្រូវបានគិតទៅតាមតារាងប្រព័ន្ធប្រាក់បៀវត្សថ្មីនៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលសាធារណៈ មន្ត្រីរាជការដែលមានដាក់ស្នែងក្នុងឆ្នាំ ២០០៣ មន្ត្រីរាជការដែលចូលនិវត្តន៍ត្រូវផ្ទេរចេញពីក្របខ័ណ្ឌ និងមន្ត្រីមរណៈដែលត្រូវកាត់បន្ថយពីអង្គភាពរបស់ខ្លួន ។ ចំពោះគំរោងចំណាយអំពីបៀវត្ស និងប្រាក់បំណាច់បុគ្គលិកអណ្តែត និងគំរោងចំណាយអំពីលាភការភ្នាក់ងារជាប់កិច្ចសន្យា គឺចាំបាច់ត្រូវតែមានសេចក្តីសំរេចអនុញ្ញាតពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**ក. បុគ្គលិកដែលកំពុងមានក្នុងពេលបច្ចុប្បន្ន**

8. ចំនួនបុគ្គលិកទាំងអស់ ដែលស្ថិតនៅក្រោមឱវាទខេត្ត ក្រុង ត្រូវបូកសរុបនៅក្នុងសលាកប័ត្រ១ ដែលបាន ភ្ជាប់ជូនមកជាមួយនេះ ។ សលាកប័ត្រនេះមានចែកជាច្រើនខ្ទង់ សំរាប់កត់ត្រានូវប្រភេទបុគ្គលិកទាំងអស់ដែល ខេត្ត ក្រុងមាន ។

9. សលាកប័ត្រ១នេះ គឺសំរាប់សរុបបុគ្គលិក មន្ត្រីរាជការ ដែលលំអិតទៅតាមអង្គភាពនីមួយៗហើយចំនួន នេះត្រូវតែផ្ទៀងផ្ទាត់ជាមួយនិងចំនួនដែលមាននៅក្នុងតារាងសរុបចំណាយ (តាមតារាង ប្រព័ន្ធ ប្រាក់បៀវត្សថ្មីនៃ ក្រុមប្រឹក្សា កំណែទំរង់រដ្ឋបាលសាធារណៈ) ។

10. ខេត្ត ក្រុងត្រូវលំអិតចំនួនបុគ្គលិកទៅតាមស្រុក ខ័ណ្ឌនីមួយៗ ដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន ។

**ខ. ការជ្រើសរើសបុគ្គលិកថ្មី**

11. អភិបាលខេត្ត ក្រុង តែងតាំងបុគ្គលិកខេត្ត ក្រុងក្នុងក្របខ័ណ្ឌនៃថវិការបស់ខេត្ត ក្រុង ទៅតាមការកំណត់នៃ លិខិតបទដ្ឋានដោយឡែកដែលមានជាធរមាន ក្រៅពីច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រ កម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៦/នស/៩៤, ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ហើយបុគ្គលិកទាំងនេះ ត្រូវគោរពតាមកាតព្វកិច្ចរបស់ភ្នាក់ងារសាធារណៈទាំងអស់ ។ ខេត្ត ក្រុងអាចសំរេច ជ្រើសរើសអោយចូលធ្វើការចំពោះបុគ្គលិកប្រភេទ "គ" និង"ឃ" ក្នុងករណីដែលចាំបាច់បំផុតបន្ទាប់ពីបានប្រើប្រាស់ អោយអស់លទ្ធភាពនូវមន្ត្រីរាជការដែលមានស្រាប់ ប្រការនេះគឺជាគោលការណ៍រួមតែប៉ុណ្ណោះ។ បច្ចុប្បន្នក្នុងពេល ដែលរាជរដ្ឋាភិបាលកំពុងដំណើរការ កែទំរង់រដ្ឋបាលសាធារណៈនិងធ្វើវិចារណកម្មលើចំនួនក្របខ័ណ្ឌមន្ត្រីរាជការនោះ ខេត្ត ក្រុងមិនត្រូវបានអនុញ្ញាតអោយជ្រើសរើសបុគ្គលិកថ្មីទេ ។

**ជំពូក១១ : ដំណើរការរដ្ឋបាល សម្ភារៈនិងការជួសជុលតូច**

12. ជំពូក១១ ប្រមូលផ្តុំរាល់ចំណាយដំណើរការរដ្ឋបាល ទិញសម្ភារៈ ជួសជុលតូច និងចំណាយជាគុណ ប្រយោជន៍របស់ខេត្ត ក្រុង ។ ឥណទានចំណាយក្នុងជំពូកនេះ ចែកចេញជាពីរផ្នែកសំខាន់ៗ ÷

មួយផ្នែកជាឥណទានសំរាប់បំរើអោយកិច្ចប្រតិបត្តិការរដ្ឋបាលសុទ្ធសាធ ដែលចាំបាច់ត្រូវគិតគូរអោយបាន ហ្មត់ចត់និងសន្សំសំចៃ ក្នុងឆ្នាំ២០០៤ ផ្អែកលើគោលការណ៍រួមរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងចំណាយសាធារណៈ ចំណាយឥណទានផ្នែកនេះ គឺអនុញ្ញាតអោយគ្រោងក្នុងកំរិតប្រហាក់ប្រហែលនិងឆ្នាំ ២០០៣ តែប៉ុណ្ណោះ ។

មួយផ្នែកទៀតជាឥណទានសំរាប់បំរើដល់គុណប្រយោជន៍របស់ខេត្ត ក្រុង ( ជំពូក ១១ ប្រការ ០១ កថាខ័ណ្ឌ ១៤ ) ក្នុងការរៀបចំមូលដ្ឋានសំភារៈនៃសេវាសាធារណៈ និងការអភិវឌ្ឍន៍របស់ខេត្ត ក្រុង ។ ផ្អែកលើផែនការអភិវឌ្ឍន៍ខេត្ត ក្រុងរបស់ក្រសួងមហាផ្ទៃ ខេត្ត ក្រុងនីមួយៗ ចាំបាច់ត្រូវរៀបចំតាមលំដាប់លំដោយ អាទិភាពនៃគំរោងចំណាយលំអិតអំពីការងារជាគុណប្រយោជន៍របស់ខេត្ត ក្រុង ដើម្បីដាក់គំរោងនេះឆ្លងការពិភាក្សា ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃក្នុងពេលធ្វើការពិភាក្សានៃគំរោងថវិកាប្រចាំឆ្នាំ ។សលាកប័ត្រ យុត្តិការដែលមានខាងក្រោមនេះ សំរាប់បង្ហាញនូវខ្ទង់ចំណាយសំខាន់ៗ ក្នុងជំពូក១១ របស់អង្គភាពនីមួយៗដែលមាន ការពាក់ព័ន្ធ ។

- អសង្ហារឹម (សលាកប័ត្រ២) : ឥណទានត្រូវបានបែងចែកតាមកន្លែងដែលប្រើប្រាស់គ្រឿងអសង្ហារឹម ដូចជា កន្លែងរដ្ឋបាល ឬនិវាសនដ្ឋាន និងតាមប្រភេទចំណាយ ដូចជាការថែទាំ ការប្រើប្រាស់ទឹក អគ្គិសនីជាដើម ។

- ចលនវត្ថុ សម្ភារៈ (សលាកបត្រ៣) : គប្បីបែងចែកដាច់ពីគ្នារវាងការទិញនិងការថែទាំ ។ ចំពោះសម្ភារៈការិយាល័យមានខ្ទង់មួយសំរាប់បំពេញក្នុងសលាកបត្រនេះ ។

- រថយន្ត (សលាកបត្រ៤) : ជាទូទៅ ចំណាយលើការប្រើប្រាស់និងថែទាំរថយន្ត មានទំហំធំធេងណាស់ បើប្រៀបធៀបនឹងប្រភេទចំណាយឯទៀត ។ ដូច្នេះអង្គភាពនីមួយៗត្រូវខិតខំយ៉ាងណា ដើម្បីខ្ទប់ចំណាយនេះកុំអោយលើសពីកំរិតដែលសមស្រប ។ ការធ្វើយុត្តិកម្មឥណទាន ត្រូវតែមានភាពច្បាស់លាស់ និងត្រូវផ្អែកទៅលើគុណភាពរថយន្ត ម៉ាករថយន្ត ផ្លាកលេខ ឆ្នាំទិញ ចម្ងាយផ្លូវដែលបានបើកបរគិតជាគីឡូម៉ែត្រ រីឯការគ្រោងឥណទានអនុញ្ញាតអោយគ្រោង បានចំពោះតែរថយន្តស្ថិតក្នុងបញ្ជីសារពើភ័ណ្ឌរបស់រដ្ឋតែប៉ុណ្ណោះ ។ ដោយហេតុនេះហើយ ត្រូវបែងចែកឥណទានដែលស្នើសុំ ទៅតាមឥណទានសំរាប់ការថែទាំ សំរាប់ប្រេងឥន្ទនៈ និងសំរាប់ប្រេងរំអិល ។ ទន្ទឹមនឹងនេះ ត្រូវធ្វើការ កត់សំគាល់ពិសេស ចំពោះរថយន្តដែលប្រើប្រាស់ជាលក្ខណៈបុគ្គលដោយមន្ត្រីរាជការពាក់ផ្លាកលេខរដ្ឋ ហើយ ប្រើប្រាស់ប្រេងឥន្ទនៈរដ្ឋ ។

- សោហ៊ុយធ្វើដំណើរ (សលាកបត្រ៥) : គឺជាប្រាក់សំរាប់ធ្វើដំណើរ របស់មន្ត្រីរាជការចេញទៅបំពេញបេសកកម្ម ។ ប្រការនេះ គឺត្រូវបែងចែកអោយដាច់ពីគ្នាទៅតាមការធ្វើដំណើរក្នុងខេត្ត ឆ្លងខេត្តនិងបេសកកម្មក្រៅប្រទេស ។ ការគ្រោងគិតសោហ៊ុយបេសកកម្ម ត្រូវមានភាពជាក់លាក់ ត្រូវឈរលើមូលដ្ឋាននៃទីកន្លែងដែលត្រូវធ្វើដំណើរ ចំនួនលើក រយៈពេល និងចំនួនបុគ្គលិកដែលត្រូវទៅបំពេញបេសកកម្ម ។

- ចំណាយជាគុណប្រយោជន៍ខេត្ត ក្រុង ដូចជាចំណាយបំភ្លឺសាធារណៈ ការប្រមូលសំរាម ថែទាំផ្លូវថ្នល់ សួនច្បារសាធារណៈ ប្រឡាយ លូទឹកជាដើម ត្រូវមានគំរោងលំអិតសំរាប់មុខសញ្ញានីមួយៗ និងត្រូវបញ្ជាក់នូវទីតាំង ភូមិ ឃុំ សង្កាត់ និងស្រុក ខ័ណ្ឌអោយបានច្បាស់លាស់ ។

- ចំណាយទទួលភ្ញៀវ ទស្សនៈកិច្ចនិងប្រជុំ ត្រូវគ្រោងអោយស្ថិតនៅក្នុងកំរិតមួយសមស្របដែលមិនប៉ះពាល់ដល់ចំណាយចាំបាច់និងមិនធ្វើអោយបាត់តុល្យភាពថវិកា ។ ចំពោះខេត្ត ក្រុង ដែលទទួលការឧបត្ថម្ភតុល្យភាពពីថវិការដ្ឋ ត្រូវគ្រោងចំណាយប្រភេទនេះក្នុងកំរិតទាបបំផុត ។

13. សលាកបត្រទាំងប៉ុន្មាននេះ មិនអាចប្រើប្រាស់ជាលិខិតយុត្តិការចាំបាច់បានគ្រប់គ្រាន់ទេ ដោយគ្រាន់តែធ្វើជាមូលដ្ឋានសំរាប់រៀបចំគំរោងថវិកាអោយស្ថិតក្នុងកំរិតមួយសមស្រប នៅក្នុងការគិតគូរនិងឆ្លើយតបទៅនឹងគោលដៅក្នុងការគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈតែប៉ុណ្ណោះ ។ សលាកបត្រមានច្រើនប្រភេទបែបនេះ គឺសំរាប់ធានាអោយបាននូវសុពលភាពនៃគំរោងចំណាយ និងភ្ជាប់ជាមួយនូវសំណុំឯកសារ ដើម្បីបង្ហាញនូវថវិកាជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

14. ជាទូទៅ ចំណាយដំណើរការរដ្ឋបាល ទិញសម្ភារៈ ការថែទាំ និងការជួសជុលតូច ត្រូវគិតគូរទៅតាមតំរូវការនៃកម្មវិធីសកម្មភាព ឬទៅតាមបទដ្ឋានសមស្រប។ ម្យ៉ាងទៀត ខេត្ត ក្រុងមិនត្រូវបំប៉ោងឥណទានដែលស្នើសុំសំរាប់ចំណាយប្រភេទនេះទេ។ ឥណទានសំរាប់ចំណាយអចិន្ត្រៃយ៍ដូចជា ទូរសព្ទ អគ្គិសនី ទឹក សម្ភារៈការិយាល័យ ប្រេងឥន្ទនៈ ត្រូវកំណត់អោយបានត្រឹមត្រូវ និងគ្រប់គ្រងយ៉ាងម៉ឺងម៉ាត់ ដើម្បីសន្សំសំចៃលើចំណាយប្រភេទនេះ ជាពិសេសនៅពេលអនុវត្តថវិកា ត្រូវជៀសវាងចំណាយលើសពីឥណទានថវិកាដែលបានគ្រោងសំរាប់មុខចំណាយនេះហើយបណ្តាលអោយជំពាក់បំណុលពីមួយឆ្នាំទៅមួយឆ្នាំទៀត ។

## ជំពូក១២ : ការឧបត្ថម្ភអោយអង្គភាពសាធារណៈរដ្ឋបាល

15. ចំណាយក្នុងជំពូកនេះសំរាប់ការឧបត្ថម្ភអោយអង្គភាពសាធារណៈរដ្ឋបាល ដែលខេត្ត ក្រុងបង្កើតឡើងហើយ ក៏រីសេវាសាធារណៈ ដែលទទួលបានពុំអាចរ៉ាប់រងបាននូវរាល់ការចំណាយចាំបាច់ ។

## ប្រភេទ ៣ : ចំណាយអន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌

16. ចំពោះចំណាយប្រភេទនេះ ត្រូវចែងលំអិតអោយបានច្បាស់លាស់ នូវគោលដៅដែលត្រូវសំរេច ។ ត្រូវពិនិត្យជ្រើសរើសចំណាយប្រភេទនេះអោយបានហ្មត់ចត់ ដោយផ្អែកលើលក្ខណៈសម្បត្តិនៃអ្នកដែលទទួលផល និង ចំនួនទឹកប្រាក់ដែលត្រូវពិនិត្យផ្តល់ជូន ។

## ប្រភេទ ៤ : ចំណាយផ្សេងៗ និងចំណាយមិនបានគ្រោងទុក

17. ចំណាយប្រភេទនេះ គឺជាការគិតគូរគ្រោងបំរុងសំរាប់ចំណាយចៃដន្យ ដែលអាចកើតមានជាយថាហេតុនៅក្នុងឆ្នាំអនុវត្ត ហើយជាទូទៅ ច្បាប់បានអនុញ្ញាតអោយគ្រោងចំណាយប្រភេទនេះក្នុងកំរិត ពី៣ទៅ៥ ភាគរយនៃចំណាយថវិកាសរុប ។ បច្ចុប្បន្នដោយថវិការដ្ឋ នៅជួបការលំបាកក្នុងការត្រៀមបំរុងសំរាប់សង បំណុលក្រុមហ៊ុនផ្គត់ផ្គង់ឯកជន សងជល់ការខូចខាតរបស់ក្រុមហ៊ុនថៃ និងត្រូវឧបត្ថម្ភតុល្យភាពដល់ថវិកាខេត្ត ក្រុង ថែមទៀតនោះ ប្រភេទចំណាយនេះ គឺអនុញ្ញាតអោយគ្រោងតែ ៣ ភាគរយសំរាប់ចំណាយមិនបានគ្រោងទុកតែប៉ុណ្ណោះ ហើយខ្ទង់ចំណាយនេះ ពេលអនុវត្តត្រូវស្នើសុំធ្វើនិយ័តភាពទៅបំពេញអោយជំពូកដទៃទៀត ដែលតំរូវការចំណាយចៃដន្យកើតមានឡើងជាយថាហេតុ ។

18. ចំណាយជាមូលធន គឺជាចំណាយសំរាប់ធ្វើហិរញ្ញប្បទានចំពោះគំរោងវិនិយោគ ដែលមានការព្រមព្រៀងគ្នាជាមុននិងសំដៅធ្វើអោយសំរេចតាមគោលដៅដែលបានដាក់ចេញ ។

19. គំរោងវិនិយោគរបស់ខេត្ត ក្រុងដែលអាចអនុវត្តបាន លុះត្រាតែគំរោងទាំងនោះ ត្រូវបានកសាងឡើងដោយផ្អែកទៅតាមកម្មវិធីវិនិយោគសាធារណៈ (PIP) រំកិលបីឆ្នាំ ២០០៣-២០០៥ តាមស្មារតីអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០០។ ការរៀបចំកម្មវិធីវិនិយោគសាធារណៈនេះ នឹងត្រូវបានណែនាំតាមសារាចរអន្តរក្រសួង ដែលធ្វើឡើងដោយក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

- ការវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេសដោយថវិកាខេត្ត ក្រុង អាចគ្រោងបានក្នុងករណីដែលខេត្ត ក្រុង មានចំណូលជាមូលធនផ្ទៃក្នុងខេត្ត ក្រុងផ្ទាល់ ។
- ការវិនិយោគដោយហិរញ្ញប្បទានពីបរទេសផ្ទាល់ ត្រូវផ្អែកលើកម្មវិធីជំនួយ ឬ គំរោងការដែលអង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលឬម្ចាស់ជំនួយទ្វេភាគីបានទៅទំនាក់ទំនងផ្ទាល់ជាមួយខេត្ត ក្រុង ដើម្បីកត់ត្រាចូលទៅក្នុងគំរោងថវិការបស់ខេត្ត ក្រុង ។ ទន្ទឹមនិងនេះក៏ត្រូវយកចិត្តទុកដាក់ផងដែរ ក្នុងការកត់ត្រារាល់ចំណាយថវិកាបដិភាគជាប្រាក់រៀល ដែលត្រូវអនុវត្តជាមួយគំរោង ដោយហិរញ្ញប្បទានពីបរទេសផ្ទាល់ ។

## III. គំរោងចំណូល ចំណាយសរុប

**20.** គំរោងចំណូល ចំណាយថវិការបស់ខេត្ត ក្រុងនីមួយៗដែលបានគិតគូរ រួមមានទាំងការធានាចំណាយដែលមិនទាន់បានធ្វើការទូទាត់ និងចំណូលដែលមិនទាន់បានប្រមូលអស់នៃការគ្រប់គ្រងក្នុងឆ្នាំមុនៗផង ។ គំរោងចំណូលចំណាយនេះ ត្រូវរៀបចំអោយមានគុណភាពពិតប្រាកដ ហើយត្រូវស្ថិតនៅក្នុងកញ្ចប់ថវិកាមួយ ដែលមានប្រភពធនធានរួមផ្សំឡើងដោយការឧបត្ថម្ភមានកំរិតកំណត់ពីថវិការដ្ឋ និងលទ្ធភាពពិតប្រាកដនៃការប្រមូលចំណូលផ្ទាល់របស់ខេត្ត ក្រុង ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០០៣

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

<u>កន្លែងទទួល</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  (ដើម្បីជូនជ្រាប)
- គ្រប់សាលាខេត្ត ក្រុង
- គ្រប់មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត ក្រុង
  (ដើម្បីមុខការ)
- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៥០៧ សហវ.ប្រក

## ប្រកាស
## ស្តីពី
## ការដកហូតអាជ្ញាប័ណ្ណឆ្នោតជាបណ្តោះអាសន្នរបស់
## ក្រុមហ៊ុនឆ្នោត ហ៊័រឈូន ឡូធើរី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១.១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០១ នស/រកម ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស/ ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រម លេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ ០១ ន.ស.រកម ០.១៩៤/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញលិខិតលេខ ៤៥៤ សជណ ចុះថ្ងៃទី ២២ ខែ មិនា ឆ្នាំ ២០០០ របស់ទីស្តីការគណរដ្ឋមន្ត្រី ស្តីពីការសុំធ្វើអាជីវកម្មឆ្នោត ៦ខ្ទង់ ប្រភេទកុំព្យូទ័រ
- បានឃើញសារាចរណែនាំលេខ ០១០ សហវ.សរ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពីកំណែទំរង់ប្រព័ន្ធគ្រប់គ្រងអាជីវកម្ម ឆ្នោត-ឡូតូ
- បានឃើញអាជ្ញាប័ណ្ណឆ្នោត ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០០ ផ្តល់ជូនក្រុមហ៊ុនឆ្នោត ហ៊័រឈូន ឡូធើរី
- បានឃើញលិខិតលេខ ១២៨ សហវ.ឧហ ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៣ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការបន្តសុពលភាពរបស់ក្រុមហ៊ុន
- បានឃើញតំរូវការចាំបាច់របស់ក្រសួង ក្នុងការគ្រប់គ្រងអាជីវកម្មឆ្នោត ឡូតូ អោយមានសណ្តាប់ធ្នាប់

## សំរេច

**ប្រការ ១ :** ដកហូតជាបណ្តោះអាសន្ននូវអាជ្ញាប័ណ្ណឆ្នោតចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០០របស់ក្រុមហ៊ុនឆ្នោត ហ្វ័ឈូន ឡូធើរី ដោយមូលហេតុក្រុមហ៊ុនពុំបានអនុវត្តតាម លិខិតលេខ ១២៨ សហវ.ឧហ ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៣ ។

**ប្រការ ២ :** ការបន្តសុពលភាពអាជ្ញាប័ណ្ណជាថ្មី គឺជាសិទ្ធរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៣ :** អគ្គលេខាធិការ នាយកខុទ្ទកាល័យ លោកប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ លោកប្រធាននាយកដ្ឋានពន្ធដារ លោកប្រធានរតនាគារជាតិ លោកប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ និងអង្គភាពពាក់ព័ន្ធ ព្រមទាំងសាម៉ីក្រុមហ៊ុន ត្រូវទទួលអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ ៤ :** ប្រកាសនេះមានសុពលភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៣

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**គាត ឈន់**

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ

  " ដើម្បីជូនជ្រាប "
- ដូចប្រការ៣

  " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥០៨ សហវ.ឧហ

## ប្រកាស
## ស្តីពី
## ការដកហូតអាជ្ញាប័ណ្ណឆ្នោតជាបណ្តោះអាសន្នរបស់ ក្រុមហ៊ុនឆ្នោត ជាអ៊ីន អន្តរជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១.១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០១ នស/រកម ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស/ ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង មានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលត្រូវបានប្រកាសអោយប្រើដោយ ព្រះរាជក្រម លេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ ០១ ន.ស.រកម ០.១៩៤/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញលិខិតលេខ ១០១០ សជណ.ផស ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៩៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការសុំបង្កើតឆ្នោតឯកជនរបស់ក្រុមហ៊ុនឆ្នោត អន្តរជាតិ ៩៥
- បានឃើញសារាចរណែនាំលេខ ០១០ សហវ.សរ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពីកំណែទំរង់ប្រព័ន្ធគ្រប់គ្រងអាជីវកម្មឆ្នោត-ឡូតូ
- បានឃើញអាជ្ញាប័ណ្ណឆ្នោតលេខ ០០៣ សហវ. ឧហ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០១ ផ្តល់ ជូនអ្នកស្រីនាយិកាក្រុមហ៊ុនឆ្នោត ជាអ៊ីន អន្តរជាតិ
- បានឃើញលិខិតលេខ ០០២ សហវ.ឧហ ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០៣ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការធ្វើអាជីវកម្មឆ្នោតរបស់ក្រុមហ៊ុនឆ្នោត ជាអ៊ីន អន្តរជាតិ
- បានឃើញលិខិតលេខ ១០៩ សហវ ឧហ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៣ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុស្តីពីការផ្តល់តារាងតុល្យភាព ឆ្នាំ ២០០២
- បានឃើញតំរូវការចាំបាច់របស់ក្រសួង ក្នុងការគ្រប់គ្រងអាជីវកម្មឆ្នោត-ឡូតូ ឱ្យមានសណ្តាប់ធ្នាប់

## សំរេច

**ប្រការ ១ :** ដកហូតជាបណ្តោះអាសន្ននូវអាជ្ញាប័ណ្ណឆ្នោតលេខ ០០៣ សហវ.ឧហ ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០០១ របស់ក្រុមហ៊ុនឆ្នោត ជាអ៊ីន អន្តរជាតិ ដោយមូលហេតុក្រុមហ៊ុនពុំបានអនុវត្តតាមលក្ខខ័ណ្ឌ នៃសេចក្តីណែនាំអនុវត្តអាជ្ញាប័ណ្ណឆ្នោត ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០១ លិខិតជូនដំណឹងលេខ ០០២ សហវ.ឧហ ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០៣ ស្តីពីដំណើរការអាជីវកម្មឆ្នោត-ឡូតូ និង លិខិតលេខ ១០៩ សហវ.ឧហ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៣ ស្តីពីការផ្តល់តារាងតុល្យភាពឆ្នាំ ២០០២ ។

**ប្រការ ២ :** ការបន្តសុពលភាពអាជ្ញាប័ណ្ណជាថ្មី គឺជាសិទ្ធរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៣ :** អគ្គលេខាធិការ នាយកខុទ្ទកាល័យ លោកប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ លោកប្រធាននាយកដ្ឋានពន្ធដារ លោកប្រធានរតនាគារជាតិ លោកប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ និង អង្គភាពពាក់ព័ន្ធ ព្រមទាំងសាម៉ីក្រុមហ៊ុន ត្រូវទទួលអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ ៤ :** ប្រកាសនេះមានសុពលភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០០៣

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**គាត ឈន់**

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ
  " ដើម្បីជូនជ្រាប "
- ដូចប្រការ ៣
  " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៥០៩ សហវ

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការបង្កើតរង្វាន់លើកទឹកចិត្តបុគ្គលិកទូទាត់បណ្ណសារ

**នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

- **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
- **រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/សន/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម លេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពី វិសោធនកម្ម មាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខនស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០២ ។

- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០២/០២១ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៣
- បានឃើញអនុក្រឹត្យ លេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ-មប្រក ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តនីបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ សហវ.ម ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តនីបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ០០៣ សហវ-ម ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ១៩៩៦ ស្តីពីរជ្ជទេយ្យបុរេប្រទាន
- បានឃើញប្រកាសលេខ ១២៩ ប្រក.សហវ ចុះថ្ងៃទី ៩ ខែមេសា ឆ្នាំ ១៩៩៧ ស្តីពីការកំណត់ទឹកប្រាក់រជ្ជទេយ្យបុរេប្រទាន ជំពូក ១១ សំរាប់ទូទាត់ចំណាយចាំបាច់ ទៅលើ ដំណើរការរដ្ឋបាល សម្ភារៈ និងការជួសជុលតូច ។
- បានឃើញតំរូវការចាំបាច់ នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន

## ស ម្រេ ច

**ប្រការ ១ :** ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទាន នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលត្រូវប្រើប្រាស់ថវិកាជំពូក១១ ដើម្បីធ្វើការទូទាត់ចំណាយទាំងឡាយដែលមានចែងក្នុងមាត្រា៦៤ នៃអនុក្រឹត្យលេខ៨២អនក្រ.បក ចុះថ្ងៃទី១៦ខែវិច្ឆិកាឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ។ ចំនួនទឹកប្រាក់ជាអតិបរិមា នៃការចំណាយ ដែលអនុញ្ញាតអោយរជ្ជទេយ្យបុរេប្រទានធ្វើការទូទាត់ត្រូវកំណត់ក្រោម៥០០.០០០រ០០( ប្រាំរយពាន់រៀលគត់) តាមចំណាត់ថ្នាក់ចំណាយនីមួយៗ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយប្រកាសអន្តរក្រសួង ។

**ប្រការ ២ :** ចំនួនទឹកប្រាក់ នៃរជ្ជទេយ្យបុរេប្រទានជំពូក ១១ សំរាប់មួយជុំ នៃឆ្នាំ ត្រូវបានកំណត់ត្រឹមចំនួន ១៤៥.០០០.០០០រ០០ (មួយរយសែសិបប្រាំលានរៀលគត់) សំរាប់ចំណាយដំណើរការ រដ្ឋបាល សំភារៈ និង ការជួសជុលតូច ។

**ប្រការ ៣ :** សេចក្តីសំរេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍

**ប្រការ ៤ :** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុ ប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋាន ព្រមទាំងប្រធានគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៣

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

ចាន់ សារុន

ចម្លងជូន :

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

- ដូចប្រការ ៤

"ដើម្បីមុខការ"

- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ

លេខៈ ០៤៧/០៣អសជ/សសរ

# សេចក្តីសំរេច

## ស្តីពី

## សវនកម្មគណនី និងសវនកម្មប្រតិបត្តិការរបស់ឃុំ-សង្កាត់

### អគ្គសវនករ នៃអាជ្ញាធរសវនកម្មជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០១/២៥៨ ចុះថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការតែងតាំងអគ្គសវនករ អគ្គសវនកររង នៃអាជ្ញាធរសវនកម្មជាតិ
- យោងអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីមូលនិធិឃុំ-សង្កាត់
- យោងអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ-សង្កាត់

### សំរេច

**ប្រការ ១ :** កំណត់នីតិវិធីនៃការធ្វើសវនកម្មផ្ទៃក្រៅលើគណនី និងប្រតិបត្តិការរបស់ឃុំ-សង្កាត់អនុលោមតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា និងតាមជំពូកទី៧ មាត្រា៥៦ នៃអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ-សង្កាត់ ។

**ប្រការ ២ :** ការធ្វើសវនកម្មដោយអនុលោមតាមស្តង់ដារនៃការធ្វើសវនកម្មទូទៅ ជាពិសេសៈ

១. អាជ្ញាធរសវនកម្មជាតិមានភាពឯករាជ្យពេញលេញក្នុងការអនុវត្តន៍ ការវិនិច្ឆ័យ បញ្ចេញយោបល់ និងផ្តល់អនុសាសន៍ដោយគ្មានលំអៀង

២. សវនករប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈសវនកម្ម

៣. អាជ្ញាធរសវនកម្មជាតិមានឯកសារភស្តុតាងគ្រប់គ្រាន់ ពាក់ព័ន្ធ និងអាចជឿជាក់បាន សំរាប់ជាមូលដ្ឋានក្នុងការសន្និដ្ឋាន និងផ្តល់អនុសាសន៍ ។

**ប្រការ ៣ :** ការធ្វើសវនកម្មឃុំ-សង្កាត់ហៅកាត់ថា **"សវនកម្ម"** រួមមាន ការត្រួតពិនិត្យលើភាពត្រឹមត្រូវជាក់លាក់ គ្រប់គ្រាន់ សុពលភាព និងភាពសមស្របនៃទិន្នន័យដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឃុំ-សង្កាត់ ក្នុងគោលបំណង ដូចខាងក្រោម :

- ធ្វើអោយប្រាកដថា ពត៌មានដែលបានបញ្ចូលទៅក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ឃុំ- សង្កាត់ ពិតជាត្រឹមត្រូវ និងអាចជឿជាក់បាន
- វាយតំលៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឃុំ-សង្កាត់ និងភាពអនុលោមជាមួយ ច្បាប់ បទប្បញ្ញត្តិ នីតិវិធីនៃការគ្រប់គ្រងជាធរមាន
- ក្នុងករណីចាំបាច់ ត្រូវផ្តល់អនុសាសន៍ដើម្បីកែលំអប្រព័ន្ធពត៌មានហិរញ្ញវត្ថុឃុំ-សង្កាត់ និងនីតិវិធីត្រួតពិនិត្យផ្ទៃក្នុង ។

**ប្រការ ៤ :** ប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់និងប្រធានរតនាគារខេត្ត-ក្រុងមានកាតព្វកិច្ចបង្កលក្ខណៈងាយស្រួលដល់អាជ្ញាធរសវនកម្មជាតិ ដើម្បីមានសិទ្ធិគ្រប់គ្រាន់ក្នុងការពិនិត្យបញ្ជីកាគណនេយ្យ ទ្រព្យសម្បត្តិ និងបុគ្គលិកព្រមទាំងពត៌មានទាំងឡាយ ដែលរក្សាទុក ឬស្ថិតក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងរតនាគារខេត្ត-ក្រុង ។

**ប្រការ ៥ :** ដំណើរការសវនកម្មត្រូវអនុវត្តដូចខាងក្រោមៈ

១. អាជ្ញាធរសវនកម្មជាតិរៀបចំនិងអនុវត្តនីតិវិធីអោយបានសមស្របដើម្បីបញ្ចេញមតិលើរបាយការណ៍ហិរញ្ញវត្ថុឃុំ-សង្កាត់នៃខេត្ត-ក្រុងនីមួយៗ និងភាពគ្រប់គ្រាន់នៃរចនាសម្ព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ឃុំ-សង្កាត់

២. សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុឆ្នាំមុន ត្រូវចាប់ផ្តើមពីខែមីនានៃឆ្នាំបន្ទាប់

៣. សវនកររៀបចំផែនការសកម្មភាពរួមមាន ប្រតិទិនការងារ និងទីកន្លែងដែលត្រូវធ្វើសវនកម្មនៅ តាមឃុំ-សង្កាត់ និងរតនាគារខេត្ត-ក្រុង

៤. ក្នុងករណីចាំបាច់សវនករអាចអញ្ជើញមេឃុំ-ចៅសង្កាត់ឡើងមកទីរួមខេត្ត-ក្រុងដើម្បីស្នើសុំពត៌មានបន្ថែម ។

**ប្រការ ៦ :** អាជ្ញាធរសវនកម្មជាតិរៀបចំរបាយការណ៍សវនកម្មសំរាប់ឃុំ-សង្កាត់នីមួយៗផ្អែកលើឯកសារ ភស្តុតាងគ្រប់គ្រាន់ ពាក់ព័ន្ធ និងអាចជឿជាក់បាន រួមមាន ដូចខាងក្រោម :

- ការធ្វើតេស្ត និងត្រួតពិនិត្យលើការងារសវនកម្មដែលបានអនុវត្ត
- ការវាយតំលៃលើសុពលភាព ភាពគ្រប់គ្រាន់ និងភាពត្រឹមត្រូវជាក់លាក់នៃបញ្ជីកាគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុព្រមទាំងផ្តល់មតិលើភាពពិត និងភាពត្រឹមត្រូវនៃរបាយការណ៍
- ការវាយតំលៃលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង
- ការអនុលោមស្របទៅតាមបទប្បញ្ញត្តិ និងល័ក្ខខ័ណ្ឌនៃកិច្ចសន្យា
- អនុសាសន៍របស់សវនករ ។

របាយការណ៍សវនកម្មត្រូវបញ្ចូលផងដែរនូវមតិពាក់ព័ន្ធជាលាយល័ក្ខអក្សររបស់ប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រធានរតនាគារខេត្ត-ក្រុង និងអភិបាលខេត្ត-ក្រុងចំពោះលទ្ធផលសវនកម្ម និងការផ្តល់អនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ។

អាជ្ញាធរសវនកម្មជាតិត្រូវផ្តល់របាយការណ៍សវនកម្មនេះជូនទៅ :

- ប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់ពាក់ព័ន្ធ
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អង្គភាពពាក់ព័ន្ធដែលអាជ្ញាធរសវនកម្មជាតិយល់ឃើញថាចាំបាច់ ។

**ប្រការ ៧ :** ក្រុមប្រឹក្សាឃុំ-សង្កាត់ មានកាតព្វកិច្ចដូចខាងក្រោម :

- តំកល់របាយការណ៍សវនកម្មនៅសាលាឃុំ-សង្កាត់សំរាប់ពត៌មានជាសាធារណៈ
- ត្រូវចាត់វិធានការកែលំអចាំបាច់ដើម្បីអនុវត្តអនុសាសន៍សវនកម្ម ។

**ប្រការ ៨ :** ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ត្រូវមានកាតព្វកិច្ចចាត់វិធានការជាក់ស្តែងដើម្បីអនុវត្តអោយមានប្រសិទ្ធភាពតាមអនុសាសន៍សវនកម្មដោយផ្សាភ្ជាប់នឹងប្រព័ន្ធហិរញ្ញវត្ថុឃុំ-សង្កាត់ ។

**ប្រការ ៩** : អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននានាចំណុះអោយអាជ្ញាធរសវនកម្មជាតិ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង-ស្ថាប័ន រដ្ឋបាលខេត្ត-ក្រុង រដ្ឋបាលមូលដ្ឋាន និង អង្គភាពពាក់ព័ន្ធ មានភារកិច្ចទទួលខុសត្រូវ ក្នុងការអនុវត្តន៍តាមប្រការទាំងឡាយនៃសេចក្តីសំរេចនេះ ។

**ប្រការ ១០** : សេចក្តីសំរេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៣

**អគ្គសវនករ**

**អ៊ុត ឈន**

**ចំលងជូន:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី

  " ដើម្បីជូនជ្រាប "

- គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា
- ដូចប្រការ៩

  " ដើម្បីអនុវត្ត "

- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**
លេខ ៧៥៧ អយក.ប្រក

# ប្រ កា ស

ស្តីពីការបើកអនុវិទ្យាល័យ មិត្តភាពខ្មែរន័រវែហ្ស ចំប៉ា
ស្ថិតនៅក្នុងឃុំចំប៉ា ស្រុកព្រៃកប្បាស ខេត្តតាកែវ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ-បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អវ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១-កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំចំប៉ា ស្រុកព្រៃកប្បាស ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៣ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តតាកែវ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## សំ រេ ច

**ប្រការ ១ :** អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថាៈ អនុវិទ្យាល័យ « មិត្តភាពខ្មែរន័រវែហ្ស ចំប៉ា » ស្ថិតនៅក្នុងឃុំចំប៉ា ស្រុកព្រៃកប្បាស ខេត្តតាកែវ ចាប់ពីឆ្នាំសិក្សា ២០០៣-២០០៤ តទៅ ។

**ប្រការ ២ :** អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

**ប្រការ ៣ :** នាយក-នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០០៣
**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
រដ្ឋលេខាធិការ

**អ៊ឹម សិទ្ធី**

<u>កន្លែងទទួល :</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  " ដើម្បីជ្រាបជាពតិមាន"
- សាលាខេត្តតាកែវ" ដើម្បីជាពតិមាន"
- ដូចប្រការ ៤
- កាលប្បវត្តិ-ឯកសារ នា.មចទ

C:\New school\K-kong2.doc

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ៧៥៥ អយក.ប្រក

# ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ ហ៊ុន សែន សិរីវង្ស

ស្ថិតនៅក្នុងឃុំសោម ស្រុកគិរីវង្ស ខេត្តតាកែវ

---

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំសោម ស្រុកគិរីវង្ស ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៣ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តតាកែវ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## សំរេច

**ប្រការ ១ :** អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ « ហ៊ុន សែន សិរីវង្ស » ស្ថិតនៅក្នុងឃុំសោម ស្រុកគិរីវង្ស ខេត្តតាកែវ ចាប់ពីឆ្នាំសិក្សា ២០០៣_២០០៤ តទៅ ។

**ប្រការ ២ :** អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអត្រាការលេខនៃអនុវិទ្យាល័យ ។

**ប្រការ ៣ :** នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ និង នាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០០៣

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន"
- សាលាខេត្តតាកែវ" ដើម្បីជាពត៌មាន "
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ ឆា.មចទ

C:\New school\K-kong2.doc

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**

លេខ..៣៧.៤.៥.....អយក.ប្រក

# ប្រកាស

ស្តីពីការប្តូរឈ្មោះវិទ្យាល័យ « អង្គប្រីយ៍ » ទៅជាវិទ្យាល័យ « ហ៊ុន សែន អង្គប្រីយ៍ »
ស្ថិតនៅក្នុងឃុំបាលិចង់ ស្រុកសំរោង ខេត្តតាកែវ

---

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អវ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំលំចង់ ស្រុកសំរោង ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០៣ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តតាកែវ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយប្តូរឈ្មោះវិទ្យាល័យ « អង្គប្រីយ៍ » បច្ចុប្បន្ន ទៅជាវិទ្យាល័យ « ហ៊ុន សែន អង្គប្រីយ៍ » ស្ថិតនៅក្នុងឃុំលំចង់ ស្រុកសំរោង ខេត្តតាកែវ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ២** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣** : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ និងនាយកវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី២៥ ខែ៧ ឆ្នាំ ២០០៣

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**រដ្ឋលេខាធិការ**

**អ៊ុំ សិទ្ធី**

<u>កន្លែងទទួល</u> :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  " <u>ដើម្បីជ្រាបជាពត៌មាន</u>"
- សាលាខេត្តតាកែវ " <u>ដើម្បីជាពត៌មាន</u>"
- ដូចប្រការ ៣
- កាលប្បវត្តិ_ឯកសារ នា.មចទ

NewSchool-Takeo-OL

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ៧៦០ អយក.ប្រក

# ប្រកាស

ស្តីពីការពង្រីកអនុវិទ្យាល័យ "ហ៊ុន សែន ១ មិថុនា" ទៅជាវិទ្យាល័យ "ហ៊ុន សែន ១ មិថុនា"
ស្ថិតនៅក្នុងឃុំពារាម ស្រុកបាទី ខេត្តតាកែវ

---

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ-បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១-កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំពារាម ស្រុកបាទី ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០៣ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តតាកែវ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## សំរេច

**ប្រការ ១** : អនុញ្ញាតអោយពង្រីកអនុវិទ្យាល័យ « ហ៊ុន សែន ១ មិថុនា » បច្ចុប្បន្ន ទៅជាវិទ្យាល័យ « ហ៊ុន សែន ១ មិថុនា » ស្ថិតនៅក្នុងឃុំពារាម ស្រុកបាទី ខេត្តតាកែវ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ២** : វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និង នាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

**ប្រការ ៣** : នាយក-នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥** : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ និងនាយកវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ,ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៣
ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន"
- សាលាខេត្តតាកែវ "ដើម្បីជាពត៌មាន
- ដូចប្រការ ៥
- កាលប្បវត្តិ-ឯកសារ នា.មចទ

C:\New school\Increase-hs.doc

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ៧៦១ អយក.ប្រក

# ប្រកាស

ស្តីពីការពង្រីកអនុវិទ្យាល័យ «ហ៊ុន សែន ឈើទាល» ទៅជាវិទ្យាល័យ «ហ៊ុន សែន ឈើទាល»
ស្ថិតនៅក្នុងឃុំរកាក្រៅ ស្រុកដូនកែវ ខេត្តតាកែវ

---

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំយុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំរកាក្រៅ ស្រុកដូនកែវ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៣ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តតាកែវ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## សំរេច

ប្រការ ១ : អនុញ្ញាតអោយពង្រីកអនុវិទ្យាល័យ « ហ៊ុន សែន ឈើទាល » បច្ចុប្បន្ន ទៅជាវិទ្យាល័យ « ហ៊ុន សែន ឈើទាល » ស្ថិតនៅក្នុងឃុំរកាក្រៅ ស្រុកដូនកែវ ខេត្តតាកែវ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ២ : វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និង នាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

ប្រការ ៣ : នាយក_នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៥ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ និងនាយកវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៣
ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពតិមាន"
- សាលាខេត្តតាកែវ" ដើម្បីជាពតិមាន
- ដូចប្រការ ៥
- កាលប្បវត្តិ_ឯកសារ នា. មចទ

C:\New school\Increase-hs.doc